ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Inform-សជណ/ 14-07-14-ថរ-បល-P.71

អគ្គិសនីកម្ពុជា

លេខ : ៤៥៣២៧ គ.ស.ណ.សកា.ថប

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជាសូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ១១ រូប ដើម្បីចូលបម្រើការងារ នៅអគ្គិសនីស្វាយរៀង នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម:

*- **លក្ខណៈសម្បត្តិបេក្ខជន** :

១- បុគ្គលិករដ្ឋបាល ០១ រូប :

+បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ ឆ្នាំ
+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធE.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90 %
+កម្រិតជំនាញ : ចាប់ពី បរិញ្ញាបត្ររងគ្រប់គ្រង ឡើងទៅ
+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
+ភាសាអង់គ្លេស : ចេះអាចប្រើការបាន

២- បុគ្គលិកបណ្តាញ (ស្វាយរៀងក្រុង, សាខាបាវិត, សាខាជីភូ និង សាខាកំពង់រោទិ៍) និង បុគ្គលិកប្រចាំការ ទូបញ្ជាព្រំដែន (សាខាកំពង់រោទិ៍) សរុបចំនួន ០៩ រូប :

+បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ ឆ្នាំ
+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធE.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90 %
+កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
+ភាសាអង់គ្លេស : ចេះអាចប្រើការបាន

៣- ភ្នាក់ងារត្រួតពិនិត្យ ០១ រូប :

+បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ ឆ្នាំ
+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធE.I.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90 %
+កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វកម្មអគ្គិសនី ឡើងទៅ
+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
+ភាសាអង់គ្លេស : ចេះអាចប្រើការបាន ។

*- **បញ្ជាក់** : បេក្ខនារីគ្រប់ខេត្ត-ក្រុង និងបេក្ខជន ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមី ប្រសិនបើ លទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាព។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៊ី (១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់

- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ (ច្បាប់ចម្លងមាន បញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត )ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល នៃទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា**

អគ្គនាយករង

ELECTRICITE DU CAMBODGE

អេង_គន្ធា